00658975

E50/3/1/2

**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជតក

ភាគីដាក់ឯកសារ: លោក ខៀវ សំផន

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: **បារាំង**

កាលបរិច្ឆេទឯកសារ: ថ្ងៃទី១ ខែមេសា ឆ្នាំ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយសាលាដំបូង

ប្រភេទនៃចំណាត់ សាធារណៈ / Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើសុំបន្ថែមពន្យារពេលដាក់ចម្លើយតប**

---

**ដាក់ដោយ៖**

**សហមេធាវីការពារក្ដីលោក ខៀវ សំផន**

លោក ស សូវាន

លោក Jacques VERGES

លោក Philippe GRECIANO

**ផ្ញើជូន៖**

**អង្គជំនុំជម្រះសាលាកំពូល**

ចៅក្រម គង់ ស្រីម

ចៅក្រម M. Motoo NOGUCHI

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម Agnieszka KLONOWIECKA-MILART

ចៅក្រម ស៊ិន រិទ្ធ

ចៅក្រម Chandra Nihal JAYASINGHE

ចៅក្រម យ៉ា ណារិន

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

ឯកសារបានទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 04 / 04 / 2011
ម៉ោង (Time/Heure): 13:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé: Uch Arun

លោក Andrew CAYLEY

# សូមគោរពអង្គជំនុំជម្រះតុលាការកំពូល

## ១. សេចក្ដីផ្ដើម

១. នៅពីថ្ងៃទី៣ ខែមិនា ឆ្នាំ២០១១ លោក ខៀវ សំផន បានដាក់ពាក្យបណ្ដឹងប្រឆាំងទៅនឹងដីកាសម្រេច ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១១ ពាក់ព័ន្ធទៅនឹងការស្នើសុំដោះលែងរូបលោកឲ្យមានសេរីភាព។[1]

២. នៅថ្ងៃទី២ ខែមិនា ឆ្នាំ២០១១ សេចក្ដីណែនាំអនុវត្តពីការដាក់ឯកសារនៅ អ.វ.ត.ក ("សេចក្ដីណែនាំអនុវត្ត") ត្រូវបានកែប្រែ ដោយរំលោភទៅលើសិទ្ធិទទួលបានការកាត់សេចក្ដីប្រកបដោយយុត្តិធម៌តែម្ដង។ តាមពិតទៅ សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានរយៈពេលកំណត់ គិតរាប់ចាប់តាំងពីថ្ងៃទទួលបានសេចក្ដីជូនដំណឹងជាភាសាផ្លូវការនោះ ត្រូវបានលុបចោល។ [2]

៣. នៅថ្ងៃទី២៨ ខែមិនា ឆ្នាំ២០១១ លោក ខៀវ សំផន ទទួលបានចម្លើយពីសហព្រះរាជអាជ្ញាដែលឆ្លើយទៅនឹងបណ្ដឹងរបស់លោក ("ចម្លើយ") ជាភាសាអង់គ្លេស និងភាសាខ្មែរប៉ុណ្ណោះ។[3] នៅថ្ងៃដដែលនោះ លោកបានស្នើសុំទៅអង្គភាពបកប្រែឯកសារ (UTI) ឲ្យផ្ដល់ជូនលោកជាបន្ទាន់នូវចម្លើយនោះជាភាសាបារាំង តែរហូតមកដល់ថ្ងៃនេះ លោកនៅតែមិនទាន់ទទួលបានឯកសារនោះនៅឡើយ។

៤. បើតាមសេចក្ដីណែនាំអនុវត្តថ្មី លោក ខៀវ សំផន មានពេល៥ថ្ងៃ ដើម្បីឆ្លើយតប គិតចាប់ពី១ថ្ងៃបន្ទាប់ពីថ្ងៃទទួលបានសេចក្ដីជូនដំណឹង "ជាភាសាខ្មែរ និងជាភាសាផ្លូវការមួយទៀត នៃ អ.វ.ត.ក"។[4] ក៏ប៉ុន្តែ ភាសាផ្លូវការដែលលោកជ្រើសយកតាំងពីដើមមក ហើយដែលទទួលស្គាល់ដោយ អ.វ.ត.ក នៅក្នុងបញ្ជីនីតិវិធីនោះ **គឺភាសាបារាំង**។

---

[1] បណ្ដឹងប្រឆាំងនឹងដីកាសម្រេចទាក់ទិននឹងការសុំដោះលែងឲ្យមានសេរីភាពជាបន្ទាន់ ថ្ងៃទី៣ ខែមិនា ឆ្នាំ២០១១ ឯកសារលេខ E50/3 ("ពាក្យស្នើសុំ")។

[2] សេចក្ដីជូនដំណឹងចុះថ្ងៃទីថ្ងៃទី៩ ខែមិនា ឆ្នាំ២០១១។ ការដាក់ឯកសារចំពោះមុខ អ.វ.ត.ក សេចក្ដីណែនាំអនុវត្ត អវតក/២០០៧/១/វិសោធនកម្មទី៦ ("សេចក្ដីណែនាំអនុវត្ត")។ សូមមើលមាត្រាថ្មី ២.២ ៧.១ ៧.២ ៨.៣ និង៨.៤។

[3] ចម្លើយរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្ដឹងរបស់លោក ខៀវ សំផន ប្រឆាំងទៅនឹងដីកាសម្រេចស្ដីពីការដោះលែងឲ្យមានសេរីភាពជាបន្ទាន់ ថ្ងៃទី២៨ ខែមិនា ឆ្នាំ២០១១ E50/3/1/1 ("ចម្លើយ") ។

[4] វិធាន ៨.៤ និង៨.៥ នៃ សេចក្ដីណែនាំអនុវត្ត។ មិនមានគូសពីក្រោមទេ នៅក្នុងឯកសារដើម។

៥. ប្រសិនបើលោកផ្លាស់ប្តូរជម្រើសដើមរបស់លោក ដោយជ្រើសយកភាសាអង់គ្លេស ប្រឆាំងទៅនឹងយោបល់របស់មេធាវីការពារក្តីរបស់លោក លោកមានពេលតែដល់ត្រឹមថ្ងៃទី៤ ខែមេសា ឆ្នាំ២០១១ប៉ុណ្ណោះ ដើម្បីអាចដាក់ចម្លើយតបរបស់លោក គឺត្រូវជា៤ថ្ងៃនៃថ្ងៃបំពេញការងារប៉ុណ្ណោះ ដើម្បីដាក់ចម្លើយតបនោះ។ អ្នកដែលដឹងពីភាពខ្វះខាតនៃអង្គភាពបកប្រែឯកសារ (UTI) ដឹងប្រាកដណាស់ថា លោក ខៀវ សំផនមិនអាចឆ្លើយតបទៅនឹងសហព្រះរាជអាជ្ញាបានឡើយ។

៦. ស្ថានភាពនេះក្លាយទៅជាចម្លែកខុសបែបបទ ក្នុងអង្គសេចក្តី ហើយមានលក្ខណៈខុសទំនងក្នុងអង្គច្បាប់។ គេមិនអាចលុបភាសាបារាំងចេញពីការងារនៃអ.វ.ត.ក ពីឯកសារដែលមានតាំងពីពេលបង្កើត អ.វ.ត.ក ពីសក្ខីកម្ម និងការងារជំនាញជាភាសាបារាំង ពាក់ព័ន្ធនឹងសំណុំឯកសារ ទាក់ទិនទៅនឹងសំណុំឯកសាររបស់ លោក ខៀវ សំផន ឡើយ ។

៧. លោក ខៀវ សំផន មិនត្រឹមតែមិនច្រានចោលភាសាបារាំងប៉ុណ្ណោះទេ ប៉ុន្តែ លោកត្រូវតែរក្សាភាសានេះ និងទំនៀមទម្លាប់ច្បាប់បារាំង ដែលជាប្រភពនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ និងច្បាប់កម្ពុជា ព្រមទាំងបទប្បញ្ញត្តិនីតិវិធីអន្តរជាតិ រួមទាំងការជូនដំណឹងជាភាសាបារាំង ដើម្បីឱ្យការកាត់សេចក្តីប្រកបដោយយុត្តិធម៌ សមធម៌ គុណភាព អាចប្រព្រឹត្តទៅបាន បន្ទាប់ពីការសិក្សាស្រាវជ្រាវ ៣០ឆ្នាំកន្លងទៅ។

## ២. ការពិភាក្សា

៨. ពាក្យថា "ដីកាបង្គាប់" ត្រូវបានកំណត់ដោយវិធានផ្ទៃក្នុង ថាជា "បទប្បញ្ញត្តិលម្អិត ដោយមានបញ្ជាក់ពីទិដ្ឋភាពផ្សេងៗនៃការងាររបស់ អ.វ.ត.ក ដែលត្រូវបានអនុម័តដោយគណៈកម្មធិការនីតិវិធី ដោយអនុលោមទៅតាមច្បាប់បង្កើត អ.វ.ត.ក ទៅនឹងកិច្ចព្រមព្រៀង និងវិធានផ្ទៃក្នុងនេះ"។[5]

៩. ក៏ប៉ុន្តែ ការអនុវត្តប្រកបដោយគ្រោះថ្នាក់ ដែលអាចបង្កឱ្យមានជាសេចក្តីណែនាំថ្មី វាផ្ទុយទាំងស្រុងទៅនឹងបទដ្ឋាន ដែលស្ថិតនៅខ្ពស់ពីលើនោះទៀត ជាពិសេសគឺការពិភាក្សា និងការពិចារណាទៅលើការបង្កើតច្បាប់តុលាការកូនកាត់អន្តរជាតិ នៅកម្ពុជា និងជាពិសេសការងារបង្កើត អ.វ.ត.ក។

[5] សទ្ទានុក្រមនៃវិធានផ្ទៃក្នុង ("វិធានផ្ទៃក្នុង") ទំព័រ៨០។ មិនមានគូសបន្ទាត់ពីក្រោមទេ នៅក្នុងឯកសារច្បាប់ដើម។

១០. តាមពិតទៅ ការអនុវត្តនៃអង្គជំនុំជម្រះនាំឲ្យឈានទៅរកការលុបបំបាត់ភាសាបារាំង ដែលធ្វើឲ្យនីតិវិធីទាំងមូលជួបនឹងបញ្ហាធំ។ ទាំងអស់នេះដើរផ្ទុយបញ្ច្រាស់គ្នាទៅនឹងឋានានុក្រមនៃបទដ្ឋាន បើទោះបីជាមាត្រា ២៦.២ នៃកិច្ចព្រមព្រៀង និងមាត្រា៤៥ ថ្មី នៃច្បាប់បង្កើត អ.វ.ត.ក បានចែងយ៉ាងច្បាស់ថា "ភាសាការងារជាផ្លូវការនៃ អង្គជំនុំជម្រះវិសាមញ្ញ មានភាសាខ្មែរ ភាសាអង់គ្លេស **និងភាសាបារាំង** ក៏ដោយ"។[6]

១១. អាក្រក់ជាងនោះទៅទៀត ការកែប្រែទៅលើដីកាបង្គាប់ អាចនាំឲ្យមានការចោទប្រកាន់ទៅលើសញ្ញាណនៃការកាត់សេចក្តីប្រកបដោយយុត្តិធម៌[7] ជាមួយនឹងការអនុវត្តជាក់ស្តែងដែលនាំឲ្យមានការដាក់បន្ទុកទៅលើជនជាប់ចោទ ជាពិសេសគឺសិទ្ធិទទួលបានភាពច្បាស់លាស់នៃដំណើរការយុត្តិធម៌ និងការទទួលបានជំនួយពីមេធាវីការពារក្តីតាមការជ្រើសរើសរបស់ខ្លួន (ចំណុចក ខាងក្រោម) និងសិទ្ធិមានពេល និងមានការផ្តល់ភាពងាយស្រួលដើម្បីរៀបចំធ្វើការការពារក្តី (ចំណុចខ)។

## ក. ការរំលោភលើសិទ្ធិជ្រើសមេធាវីការពារក្តី និងការរំលោភលើភាពច្បាស់លាស់នៃដំណើរការយុត្តិធម៌

១២. កិច្ចព្រមព្រៀង ច្បាប់បង្កើតអ.វ.ត.ក និងវិធានផ្ទៃក្នុង មានចែងពីសិទ្ធិរបស់ជនទាំងឡាយណាដែលត្រូវបានសង្ស័យ ឬត្រូវបានចោទប្រកាន់ ថាមានសិទ្ធិទទួល មេធាវីការពារតាមការជ្រើសរើសរបស់ខ្លួន។[8]

១៣. តាមវិធាន២១ នៃវិធានផ្ទៃក្នុង ៖ "ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាល ទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យ**ការពារជានិច្ច**ដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ (...)"។

---

[6] មិនមានគូសបន្ទាត់ពីក្រោមទេ នៅក្នុងឯកសារច្បាប់ដើម។

[7] មាត្រា១២ និង១៣ នៃកិច្ចព្រមព្រៀង មាត្រា៣៣ និង៣៥ នៃច្បាប់បង្កើត អ.វ.ត.ក មាត្រា២១ នៃវិធានផ្ទៃក្នុង។

[8] មាត្រា១៣.២ នៃកិច្ចព្រមព្រៀង មាត្រា ៣៥ ឃ ថ្មី នៃច្បាប់បង្កើត អ.វ.ត.ក មាត្រា២១ ឃ នៃវិធានផ្ទៃក្នុង

១៤. ក៏ប៉ុន្តែ លោក ខៀវ សំផន ដែលមានវប្បធម៌ខ្មែរ និងបារាំង ធ្លាប់ជានិស្សិតនៅទីក្រុងប៉ារីស ទទួលបានការបណ្តុះបណ្តាលនៅសាកលវិទ្យាល័យសរបោន ទទួលបានការអញ្ជើញជាច្រើនដងទៅកាន់ប្រទេសបារាំងដើម្បីកិច្ចសម្ភាស សន្និសីទ ការជួបប្រជុំនយោបាយផ្សេងៗ បានធ្វើការសម្រេចចិត្តដ៏ច្បាស់លាស់ក្នុងការជ្រើសរើសយកមេធាវីការពាររូបលោកពីប្រទេសមួយដែលប្រកាន់យកនូវការគោរពសិទ្ធិមនុស្ស។ លោកបានរៀបចំការការពារខ្លួនលោក ជាមួយនឹងការការប្រឹក្សាអន្តរជាតិ ជាភាសាបារាំង ជាមួយនឹងអ្នកជំនាញ ទីប្រឹក្សា និងសាក្សីដែលនិយាយភាសាបារាំង។ អ្នកទាំងអស់គ្នាសុទ្ធតែមានបំណងចង់បង្ហាញយោបល់ ប្រកបដោយភាពម៉ឺងម៉ាត់ផ្នែកច្បាប់ និងភាសាច្បាប់។[9]

១៥. ការបកស្រាយមិនត្រឹមត្រូវទៅលើសេចក្តីណែនាំអនុវត្ត អាចប៉ះពាល់ដល់ដំណើរការនៃសវនាការ ហើយបញ្ហាប៉ះពាល់ជាយថាហេតុនោះវាកាន់តែខ្លាំងថែមទៀត ប្រសិនជាយើងមិនលើកយកវាមកពិនិត្យឲ្យបានច្បាស់លាស់ជាបន្ទាន់ មុនចាប់ផ្តើមសវនាការទេនោះ។

១៦. ការបញ្ជាក់ឲ្យបានច្បាស់ពីកាអនុវត្តពិតជាចាំបាច់ខ្លាំងណាស់ សម្រាប់ធានាឲ្យបាននូវសច្ចភាពផ្លូវច្បាប់នៃការកាត់ក្តី ដែលអនុលោមទៅតាមមាត្រា ៣.១ នៃកិច្ចព្រមព្រៀង ដែលចែងថា “សិទ្ធិរបស់ជនជាប់ចោទដែលមានចែងនៅក្នុង មាត្រា១៤ និង១៥ នៃកតិកាសញ្ញាអន្តរជាតិពាក់ព័ន្ធនឹងសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៅឆ្នាំ១៩៦៦ [“PIDCP”] ត្រូវបានគោរព <u>នៅក្នុងអំឡុងពេលកាត់សេចក្តីទាំងស្រុង</u>”។[10]

## ខ. ការរំលោភលើសិទ្ធិទទួលបានពេលវេលាគ្រប់គ្រាន់ និងភាពងាយស្រួល ដើម្បីរៀបចំត្រៀមការពារក្តី

១៧. ដូច PIDCP ដែរ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា កិច្ចព្រមព្រៀង និងច្បាប់បង្កើត អ.វ.ត.ក ទទួលស្គាល់ថា រាល់ជនជាប់ចោទដោយបទល្មើសព្រហ្មទណ្ឌ មានសិទ្ធិប្រកប

---

[9] លោក ខៀវ សំផន បានជ្រើសរើសយកមេធាវីរបស់លោក ក្នុងចំណោមបញ្ជីមេធាវីបេក្ខជន ហើយលោកមិនបានតម្រូវថាជ្រើសយកមេធាវីដែលចេះភាសាផ្លូវការលើសពីមួយក្នុងចំណោមភាសាទាំងបីឡើយ ទោះជាចំពោះបេក្ខជនបរទេស ឬបេក្ខជនកម្ពុជាក្តី ៖ សូមអានវិធាន១១.៤.គ.៥ និង ១១.៤.ឃ នៃ វិធានផ្ទៃក្នុង ។

[10] មិនមានគូសបន្ទាត់ពីក្រោមទេ នៅក្នុងឯកសារច្បាប់ដើម។

ដោយសមភាព ក្នុងការទទួលបានពេលវេលាគ្រប់គ្រាន់ និងភាពងាយស្រួល ដើម្បីត្រៀមការពារក្តី។[11]

១៨. ការចូលប្រើប្រាស់សំណុំឯកសារជាភាសាបារាំង សំណុំឯកសាររដ្ឋបាល ឬសំណុំឯកសារវិវាទដែលតាក់តែងឡើងជាភាសាបារាំង ការចូលប្រើប្រាស់ច្បាប់ និងប្រភពឯកសារតុលាការនៃមេធាវីការពារបារាំងរបស់លោក សុទ្ធតែជាការបង្កភាពងាយស្រួលដល់ត្រៀមការពារក្តីរបស់លោក។

១៩. លោក ខៀវ សំផន និងក្រុមមេធាវីការពារក្តីរបស់លោក មានបំណងចង់ផ្តល់ចម្លើយយ៉ាងច្បាស់លាស់បំផុត ទៅលើអង្គហេតុ និងអង្គច្បាប់ ទៅនឹងអំណះអំណាងរបស់សហ-ព្រះរាជអាជ្ញា និងតាមបំណងប្រាថ្នារបស់ចៅក្រមទាំងអស់ និងជនរួមជាតិរបស់លោក។

២០. លោក ខៀវ សំផន បានបាត់បង់ប្រយោជន៍ជាច្រើនដោយសារតែសហព្រះរាជអាជ្ញា និងក្រុមការពារក្តីដទៃទៀត ដែលមានវប្បធម៌អង់គ្លេស និយាយតែភាសាអង់គ្លេស ក៏ប៉ុន្តែ**ប្រព័ន្ធច្បាប់ Civil law និងចំណេះដឹងវិទ្យាសាស្ត្របារាំង** អាចធ្វើឱ្យគេយល់បានច្បាស់ពីភាពស្រដៀងគ្នាក្នុងច្បាប់ និងមុខងាររបស់លោក ខៀវ សំផន ក្នុងសម័យខ្មែរក្រហម ព្រមទាំងការចូលរួមរបស់លោក ដើម្បីសន្តិភាព និងប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា ដែលមានជាប់ទាក់ទងផងដែរនឹងប្រទេសបារាំង។

២១. ម៉្យាងវិញទៀត ក្រុមមេធាវីការពារក្តី មិនអាចបំពេញការងារតែជាភាសាបារាំងតែមួយបានឡើយ ពីព្រោះថាតួនាទីរបស់មេធាវីកម្ពុជាមិនមែនត្រឹមតែប្រើពេលវេលាខ្លួនដើម្បីសម្រាប់តែបកប្រែឯកសារ ឬបកប្រែផ្ទាល់មាត់ប៉ុណ្ណោះឡើយ។

២២. ប្រសិនបើលុបភាសាបារាំងចោល លោក ខៀវ សំផន មិនអាចធានាបាននូវការការពារក្តីរបស់លោក ប្រកបដោយប្រសិទ្ធិភាព និងពេញលេញឡើយ។

២៣. ទីបញ្ចប់ កាតព្វកិច្ចក្នុងការដាក់ឯកសារជាពីរភាសា **វាកាត់បន្ថយ**ថិរវេលាកំណត់យ៉ាងច្រើន និងចាប្រព័ន្ធរួចស្រេចទៅហើយ ហើយលើសពីនោះទៅទៀត អង្គភាពបកប្រែឯកសារ (UTI) មានការងារច្រើនលើសលុប មិនមានបុគ្គលិកគ្រប់គ្រាន់ទេ ហើយក៏មិនធ្វើការនៅចុងសប្តាហ៍ដែរ។

---

[11] មាត្រា១៤.៣ ខ នៃកតិកាសញ្ញា PIDCP មាត្រា៣១នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា១៣.១ នៃកិច្ចព្រមព្រៀង មាត្រា៣៥ថ្មីនៃច្បាប់បង្កើត អ.វ.ត.ក។

២៤. រួមសេចក្តីទៅ លោក ខៀវ សំផន មិនទទួលបានទាំងការបង្កភាពងាយស្រួល ទាំងពេលវេលាចាំបាច់ ដើម្បីរៀបចំការពារក្តីរបស់លោកឡើយ ព្រោះថា ចម្លើយរបស់សហព្រះរាជអាជ្ញានៅកំពុងបកប្រែជាភាសាបារាំងនៅឡើយ ទោះបីជានៅសល់ពេលតែមួយថ្ងៃ (ថ្ងៃបំពេញការងារ) ដើម្បីដាក់ចម្លើយតប ជាពីរភាសាផ្លូវការដែលបានជ្រើសរើសក្តីសកម្មភាពនេះពិតជា**មិនអាចធ្វើទៅរួចឡើយ**។

២៥. ដោយសារតែមូលហេតុទាំងអស់នេះ លោក ខៀវ សំផន ត្រូវបានបង្ខំឱ្យស្ថិតនៅក្នុងស្ថានភាពមិនអាចឆ្លើយតបទៅនឹងឯកសារជាភាសាអង់គ្លេស ចំនួន១២ទំព័រ។

២៦. ដូច្នេះ លោកមិនអាចទទួលបាននូវការកាត់សេចក្តីប្រកបដោយយុត្តិធម៌ឡើយ។

## ហេតុដូច្នេះ

២៧. សូមឱ្យអង្គជំនុំជម្រះសាលាកំពូល មេត្តា៖

- ចាត់ទុកថា លោក ខៀវ សំផន បានជ្រើសរើសភាសាបារាំងដើម្បីការពាររូបលោក និងថា តុលាការតែងតែបានផ្តល់សិទ្ធិទទួលបានការបកប្រែជាភាសាបារាំង នៅក្នុងការគណនាថិរវេលាកំណត់

- ប្រកាស និងវិនិច្ឆ័យថា**ការបកប្រែផ្ទាល់មាត់** នៃសេចក្តីបង្គាប់អនុវត្ត ត្រូវធានាសិទ្ធិមូលដ្ឋានបំផុត របស់លោកលោក ខៀវ សំផន ជាពិសេសសិទ្ធិរបស់លោកក្នុងការទទួលបាន **ការបកប្រែ និងការការពាររូបលោក** ជាភាសាបារាំង

- អនុញ្ញាតឱ្យ លោក ខៀវ សំផន ដាក់ចម្លើយតប យ៉ាងហោចណាស់ឱ្យបាន៥ថ្ងៃ គិតចាប់ពីពេលទទួលបានសេចក្តីជូនដំណឹងនូវចម្លើយ ជាភាសាបារាំង

- បង្គាប់ឲ្យដាក់ចម្លើយតប គិតចាប់ពីពេលទទួលបានសេចក្តីជូនដំណឹងជាភាសាបារាំងនូវដីកាសម្រេច។

## រក្សាសិទ្ធិកែប្រែគ្រប់យ៉ាង

## និងដើម្បីយុត្តិធម៌

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| | មេធាវី ស សុវាន | ភ្នំពេញ | |
| | មេធាវី Jacques VERGÈS | ប៉ារីស | |
| | មេធាវី Philippe GRECIANO | ប៉ារីស | |